www.kidworship.kr

# យ៉ាកុប ទី១

- 9th Story -



58Page

**Nar** អីសាកនិងរេបិកាបង្កើតបានកូនភ្លោះពីរនាក់។
កូនប្រុសបង មានពណ៌ក្រហម ស្បែកដូចរោមសត្វ។
អ៊ីសាកដាក់ឈ្មោះគាត់ថា«អេសាវ»។ ប្អូនប្រុសរបស់អេសាវ
កើតមកទាំងតោងកែងជើងរបស់អេសាវជាប់។
អ៊ីសាកដាក់ឈ្មោះគាត់ថា «យ៉ាកុប»។
ទោះបីអេសាវនិងយ៉ាកុបកើតមកជាមួយគ្នាក៏ដោយ
ប៉ុន្តែពួកគេខុសគ្នាឆ្ងាយណាស់។
អេសាវមានកំលាំងខ្លាំងនិងរហ័ស ហើយចូលចិត្តទៅក្នុងព្រៃ។
អេសាវ បានធំឡើង ក្លាយជាអ្នកប្រមាញ់ដ៏ស្ទាត់ជំនាញម្នាក់។
អ៊ីសាកស្រឡាញ់អេសាវណាស់។ ចំណែកយ៉ាកុបវិញ
ជាមនុស្សស្ងប់ស្ងាត់ ដែលចូលចិត្តនៅតែផ្ទះ។
យ៉ាកុប បានមើលថែនិងចិញ្ចឹមសត្វ ហើយជួយធ្វើ កាងារផ្ទះទៀត។
ឯម្តាយរបស់គាត់ស្រឡាញ់គាត់ណាស់។

---



59Page

**Nar** ថ្ងៃមួយ យ៉ាកុបកំពុងស្លសម្លមួយឆ្នាំង។
អេសាវទើបមកពីបាញ់សត្វវិញ ពេលនោះ អេសាវឃ្លានខ្លាំងណាស់។
**Esau** យ៉ាកុប! ឱ្យបងសុំញ៉ាំសម្លនោះបានទេ?
**Jacob** ខ្ញុំនឹងឱ្យបងញ៉ាំសម្លនេះ
បើសិនជាបងលក់សិទ្ធិជាកូនច្បងរបស់បងមកឱ្យខ្ញុំ ។
**Esau** សិទ្ធិជាកូនច្បងរបស់បងឬ?? ល្អ! យល់ព្រម។
តើសិទ្ធិជាកូនច្បងមានប្រយោជន៏អ្វីដល់បង
បើពេលនេះ បងឃ្លានជិតស្លាប់ទៅហើយ?
**Nar** អេសាវមិនបានឲ្យតម្លៃលើសិទ្ធិជាកូនច្បងរបស់គាត់ទេ។
ហេតុនេះ អេសាវក៏បានធ្វើតាមការសុំរបស់យ៉ាកុប។

---



60Page

**Nar** យូរឆ្នាំកន្លងផុតទៅ អ៊ីសាកក៏កាន់តែចាស់ ឯភ្នែករបស់គាត់
ក៏ខ្សោយទៅ មើលអ្វីមិនឃើញទៀតឡើយ។
ថ្ងៃមួយ អ៊ីសាកប្រាប់អេសាវថា៖
**Isaac** អេសាវអើយ! ចូរកូនចេញទៅព្រៃបាញ់សត្វ យកមកធ្វើម្ហូបឲ្យពុកហូប។
ពេលពុកហូបហើយ ពុកនឹងឲ្យពរដល់កូន មុនពេលពុកស្លាប់។
**Esau** ពិត-ឬ? ខ្ញុំនឹងទៅឲ្យបានលឿនបំផុត។

**Nar** អេសាវបានចេញទៅបាញ់សត្វទាំងមានចិត្តរីករាយ។

---



61Page

**Nar** ពេលដែលអ៊ីសាកប្រាប់អេសាវ នោះរេបិកាជាប្រពន្ធ
ក៏បានស្តាប់លឺដែរ។ ដោយរេបិកាស្រឡាញ់យ៉ាកុបខ្លាំងជាងអេសាវ
នោះនាងគិតក្នុងចិត្តថា

**Rebekah** វាជាការល្អបំផុត បើយ៉ាកុបជាអ្នកទទួលបានពរនេះ។.

**Nar** ក្រោយមក រេបិកាបានហៅយ៉ាកុបហើយប្រាប់ថា

**Rebekah** ម៉ែនឹងរៀបចំម្ហូបដ៏ឆ្ងាញ់ឲ្យពុករបស់កូន។
បន្ទាប់មក ចូរកូនយកវាទៅជូនគាត់ ដើម្បីឲ្យគាត់អោយពរដល់កូន
មុនពេលគាត់ស្លាប់។

**Jacob** ម៉ែ! បងអេសាវ មានរោម តែខ្ញុំមានស្បែករលោង។
តើនឹងមានអ្វីកើតឡើង បើពុកស្ទាបស្បែកខ្ញុំ?
ពេលនោះ ពុកនឹងដឹងភ្លាមថា ជាខ្ញុំ មិនមែនជាបងអេសាវទេ។

**Rebekah** កុំបារម្ភអី! ម៉ែមានវិធីមួយ។

**Nar** រេបិកាបានធ្វើម្ហូបពីកូនពពែតូចដ៏ឈ្ងុយឆ្ងាញ់តាមរបៀប
ដែលអ៊ីសាកចូលចិត្ត។ បន្ទាប់មក រេបិកាយកខោអាវរបស់អេសាវ
ទៅឲ្យយ៉ាកុបពាក់។

---



62Page

**Nar** យ៉ាកុបយកម្ហូបដ៏ឆ្ងាញ់ ដែលម៉ែគាត់បានធ្វើ ទៅឲ្យពុកគាត់។

**Jacob** ពុកពុក!

**Isaac** នរណាគេហ្នឹង?

**Jacob** ខ្ញុំជាអេសាវ។ ពុកងើបមក ហូបសម្លពីសាច់ ដែលខ្ញុំបាញ់បាន
ហេតនេះទើបពុកនឹងឲ្យពរដល់ខ្ញុំ។

**Nar** ពេលនោះ យ៉ាកុបភ័យថា ពុកគាត់អាចចំណាំគាត់បានណាស់។

**Isaac** ចូលមកជិតពុកមក ឲ្យពុកស្ទាបមើលថា ពិតជាអេសាវកូនប្រុសពុក
មែនឬមិនមែន។

**Nar** ពុករបស់យ៉ាកុប ក៏បានស្ទាបគាត់។

**Isaac** សម្លេងជាយ៉ាកុប ប៉ុន្តែដៃជាអេសាវ។
ខ្ញុំប្រហែលជាច្រឡំហើយមើលទៅ។

**Nar** អ៊ីសាកចាស់ណាស់ហើយ។ ដោយភ្នែកគាត់ខ្សោយពេក
ទើបគាត់មិនអាចមើលស្គាល់ថា ជាយ៉ាកុបទេ។
អ៊ីសាកក៏ជឿថា គាត់កំពុងនិយាយជាមួយអេសាវមែន
ទើបអ៊ីសាកហូបអាហាររួចហើយ គាត់ក៏ឲ្យពរយ៉ាកុបទៅ។

---



63Page

**Nar** មួយសន្ទុះមក អេសាវបានមកពីបរបាញ់វិញ។
អេសាវបានធ្វើម្ហូប រួចក៏យកទៅឲ្យពុកគាត់ដែរ។

**Isaac** នរណាគេហ្នឹង?

**Esau** ពុកពុក! ខ្ញុំគឺអេសាវ!

**Isaac** យ៉ាងម៉េចនឹង? ពុកទើបតែឲ្យពរដល់កូនហើយតើ!

**Nar** ពេលឮដូច្នេះ អេសាវឈឺចិត្តយ៉ាងខ្លាំងហើយយំ។

**Esau** ពុកអើយ! យ៉ាកុបបានបោកបញ្ឆោតខ្ញុំពីរដងរួចទៅហើយ។
លើកទី១ យ៉ាកុបបានបោកយកសិទ្ធិជាកូនច្បងរបស់ខ្ញុំ
ពេលនេះ យ៉ាកុបបានបោកយកពររបស់ខ្ញុំទៀត។
ដូច្នេះ សូមពុកឲ្យពរមកខ្ញុំផង!

**Isaac** ពុកបានអោយពរនោះដល់យ៉ាកុបបាត់ទៅហើយ ធ្វើម្តេចទើបពុក
ឲ្យពរដល់កូនបានទៀត?

**Nar** អេសាវបានយំយ៉ាងខ្លាំង។ ហើយអេសាវបានស្អប់យ៉ាកុបជាប្អូនប្រុស
របស់គាត់។ អេសាវក៏គិតថា

**Esau** ចាំមើល! ខ្ញុំនឹងសម្លាប់យ៉ាកុបបន្ទាប់ពីពុកស្លាប់ទៅ។

**Nar** របិកាបានដឹងគំរោងការអេសាវ ហេតុនោះ របិកាប្រាប់យ៉ាកុប
ឲ្យរត់ចេញពីផ្ទះទៅផ្ទះពូគាត់ ដើម្បីស្នាក់នៅទីនោះទៅ។